NSW Health

# សូមចាក់វ៉ាក់សាំង ឱ្យបានទាន់ពេល

## ផ្តល់កិច្ចការពារដ៏ល្អបំផុត ដល់ទារករបស់អ្នក



## ការរក្សាទុកកំណត់ត្រា

អ្នកនឹងត្រូវការផ្តល់កំណត់ត្រានៃការចាក់ថ្នាំបង្ការរោគរបស់កូនអ្នក ទៅកន្លែងថែទាំកុមារ សាលាមត្តេយ្យ និងសម្រាប់ការចុះឈ្មោះចូលរៀន។

ឳពុកម្តាយអាចស្នើសុំច្បាប់ចម្លងនៃលិខិតបញ្ជាក់ពីប្រវត្តិចាក់ថ្នាំបង្ការរោគ AIR ( AIR Immunisation History Statement ) របស់កូនពួកគេនៅពេលណាមួយ ( មុនពេលកូនរបស់ពួកគេចូលអាយុ 14 ឆ្នាំ )៖

- ប្រើគណនី Medicare តាមអនឡាញរបស់ពួកគេតាមរយៈ myGov my.gov.au
- ដោយប្រើកម្មវិធី Medicare Express Plus App humanservices.gov.au/individuals/subjects/express-plus-mobile-apps
- ទូរសព្ទទៅ បណ្តាញទូរសព្ទសាកសួរទូទៅរបស់ AIR តាមលេខ **1800 653 809**

# តើអ្នកដឹងទេថាជាង 94% នៃកុមារក្នុងរដ្ឋញូវសៅវែល បានចាក់ថ្នាំបង្ការរោគពេញលេញ ?

## ទីកន្លែងចាក់វ៉ាក់សាំង

ការចាក់វ៉ាក់សាំងមានផ្តល់ជូនដោយ៖

- វេជ្ជបណ្ឌិតព្យាបាលជំងឺទូទៅ
- សាលាក្រុងមួយចំនួន
- មជ្ឈមណ្ឌលសុខភាពសហគមន៍មួយចំនួន

ប្រសិនបើអ្នកមិនប្រាកដអំពីសេវាកម្មអ្វីខ្លះដែលមានផ្តល់ជូនក្នុងតំបន់របស់អ្នក អ្នកអាចទាក់ទងមកអង្គភាពសុខភាពសាធារណៈដែលនៅជិតអ្នកជាងគេ តាមទូរសព្ទលេខ **1300 066 055**។




ខែកញ្ញា ឆ្នាំ 2021 © NSW Health.
SHPN (HP NSW) 210822-13.

## កុំពន្យារពេលចាក់វ៉ាក់សាំង

វ៉ាក់សាំងមានសុវត្ថិភាព និងផ្ដល់កិច្ចការពារដ៏ល្អបំផុតដល់កូនរបស់អ្នក ប្រសិនបើពួកគេបានចាក់ទាន់ពេលយោងតាមគម្រោងចាក់ថ្នាំបង្ការរោគ រដ្ឋញូវសៅវែល។

ការកំណត់ពេលនៃរាល់ការចាក់វ៉ាក់សាំងសម្រាប់កុមារត្រូវបានជ្រើសរើសដោយអ្នកជំនាញយ៉ាងប្រុងប្រយ័ត្នដើម្បីធ្វើឱ្យប្រាកដថា កុមារត្រូវបានការពារនៅចំអាយុដែលជំងឺកើតមានជាទូទៅបំផុត ឬធ្ងន់ធ្ងរបំផុត។

កុំពន្យារពេលចាក់វ៉ាក់សាំងឱ្យកូនរបស់អ្នក ប្រសិនបើពួកគេហៀរសម្បោរ ឬមានជំងឺគ្រុនផ្ដាសាយស្រាល។ សូមពិគ្រោះជាមួយវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់អ្នកដើម្បីប្រាកដថា កូនរបស់អ្នកត្រូវបានការពារទាន់ពេលតាមដែលអាចធ្វើទៅបាន។

**រក្សាកូនរបស់អ្នកឱ្យមានសុវត្ថិភាព សូមចាក់វ៉ាក់សាំងឱ្យបានទាន់ពេល**



## ហេតុអ្វីបានជាត្រូវចាក់វ៉ាក់សាំង

- ការចាក់វ៉ាក់សាំង គឺជាវិធីល្អបំផុតដើម្បីការពារកូនរបស់អ្នក ពីការកើតជំងឺធ្ងន់ធ្ងរនានា។
- ការចាក់វ៉ាក់សាំងការពារកូនរបស់អ្នក និងសហគមន៍របស់អ្នក។
- ការចាក់វ៉ាក់សាំងជួយគ្រប់គ្រងជំងឺធ្ងន់ធ្ងរ ដែលអាចបង្ការដោយវ៉ាក់សាំង។

## ពេលណាត្រូវចាក់វ៉ាក់សាំង

គម្រោងចាក់ថ្នាំបង្ការរោគរដ្ឋញូវសៅវែលបានណែនាំថា កូនក្មេងត្រូវចាក់វ៉ាក់សាំង នៅពេលពួកគេមានអាយុដូចខាងក្រោម៖

- នៅពេលកើតមក
- 6 សប្ដាហ៍
- 4 ខែ
- 6 ខែ
- 12 ខែ
- 18 ខែ
- 4 ឆ្នាំ

វាសំខាន់ដែលត្រូវចាក់វ៉ាក់សាំងឱ្យកូនរបស់អ្នកបានទាន់ពេល។ ដូច្នេះ សូមកក់ទុកជាមុនដោយធ្វើការណាត់ជួបជាមួយវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់អ្នក ហើយកត់ទុកកាលបរិច្ឆេទដើម្បីចាក់វ៉ាក់សាំង។

## បន្ទាប់ពីការចាក់វ៉ាក់សាំង

វ៉ាក់សាំងមានសុវត្ថិភាព និងប្រសិទ្ធភាពក្នុងកិច្ចការពារកូនរបស់អ្នកប្រឆាំងនឹងជំងឺធ្ងន់ធ្ងរ។

ពេលខ្លះបន្ទាប់ពីចាក់វ៉ាក់សាំងរួច កូនរបស់អ្នកអាចមានផលប៉ះពាល់បន្ទាប់បន្សំស្រាល ដូចជាឈឺចាប់ ហើម និងឡើងក្រហមនៅកន្លែងចាក់ថ្នាំ។

ប្រសិនបើអ្នកព្រួយបារម្ភ អំពីផលប៉ះពាល់បន្ទាប់បន្សំដែលអាចកើតមាន សូមពិគ្រោះជាមួយវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់អ្នក។

## វ៉ាក់សាំងបង្ការជំងឺគ្រុនផ្ដាសាយ គឺឥតគិតថ្លៃសម្រាប់កុមារ

វ៉ាក់សាំងបង្ការជំងឺគ្រុនផ្ដាសាយធំ ( ជំងឺគ្រុនផ្ដាសាយ ) គឺជាកិច្ចការពារដ៏ល្អបំផុតរបស់កូនអ្នក ប្រឆាំងនឹងជំងឺគ្រុនផ្ដាសាយធ្ងន់ធ្ងរ។ វ៉ាក់សាំងនេះគឺឥតគិតថ្លៃសម្រាប់ក្មេងអាយុពី 6 ខែ ទៅអាយុក្រោម 5 ឆ្នាំ។ វ៉ាក់សាំងបង្ការជំងឺគ្រុនផ្ដាសាយ ត្រូវការផ្ដល់ឱ្យជារៀងរាល់ឆ្នាំ ដើម្បីការពារប្រឆាំងនឹងប្រភេទជំងឺគ្រុនផ្ដាសាយទូទៅបំផុត។ វ៉ាក់សាំងនេះអាចរកបានពីអ្នកផ្ដល់ការចាក់ថ្នាំបង្ការរោគធម្មតារបស់អ្នក។

សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលគេហទំព័រ
**health.nsw.gov.au/flu**